# ឆ្ពោះទៅក្នុងពន្លឺ
# ដ៏អស្ចារ្យរបស់ព្រះ



## ការសិក្សាអំពីព្រះគម្ពីរ

By Kirk Bates, Al Gossan, Jr. and Galen Walters

បកស្រាយដោយ : លោក ស៊ិទ្ធ រីវុធ

មើលកែដោយ : អ្នកស្រី ហួត ម៉ាឆ្នុំ និង លោក ហុង ឆៀវ

# សេចក្តីផ្តើម

ការសិក្សាក្នុងព្រះគម្ពីរខាងមុខនេះ បានរៀបចំឡើងដើម្បីពន្យល់ ពីផែនការណ៍ស្រោចស្រង់ តាមវិធីងាយក្នុងមេរៀនសង្ខេបតែមួយ ដោយមានគ្រូម្នាក់ជួយដឹកនាំ ក្នុងការពិភាក្សាឬសិក្សាដោយខ្លួនឯង។ មេរៀននេះអាចចែកជាពីរផ្នែក ដោយមានការសម្រាកខ្លីមួយចន្លោះពេលនិមួយៗប្រហែល៣០នាទី។ កន្លែងល្អសំរាប់ការសម្រាកនេះគឺនៅក្រោយអត្ថបទអំពី "ការឆ្លងៈទៅក្នុងកាសិក្សាអំពីព្រះយេស៊ូវ" ។

អ្នកដែលបានចូលរួមក្នុងការសិក្សានេះ ត្រូវឱ្យមានសៀវភៅនេះមួយ ជាមួយនិងព្រះគម្ពីរ និងខ្មៅដៃមួយឬក៏ប៊ិច បន្ទាប់ពីបានអានព្រះគម្ពីរហើយនោះ សិស្សម្នាក់ៗត្រូវសួរឱ្យឆ្លើយ ហើយបំពេញនៅកន្លែងដែលបានទុកចន្លោះនៅក្នុងសៀវភៅនៃការសិក្សាព្រះគម្ពីរនោះ ការពន្យល់និងអត្ថន័យបន្ថែមនៃព្រះគម្ពីរ និងមានសរសេរជាលេខក្នុងវង់ក្រចក ដែលនឹងផ្តល់បន្ថែមនៅទំព័រទី១០ នៃសៀវភៅនេះ ។

ឆ្លៀតឱកាសនេះ យើងខ្ញុំសូមឱ្យអ្នកដែលបានចូលរួមក្នុងការសិក្សាទាំងអស់គ្នានេះ ឧទ្ទិសសូមឱ្យព្រះជួយឱ្យយើងបានយល់នូវពាក្យរបស់ព្រះអង្គ ដូចកាលដែលស្តេចដាវីឌបានឧទ្ទិសស្ថាន "សូមបើកភ្នែកទូលបង្គំ ដើម្បីឱ្យបានយល់នូវច្បាប់របស់ព្រះអង្គ" ហើយសូមឱ្យព្រះអង្គផ្តល់ពរជ័យចំពោះយើងរាល់គ្នាដែលនឹងធ្វើដំណើរ " ឆ្លងៈទៅក្នុងពន្លឺដ៏អស្ចារ្យរបស់ព្រះ"

"ដើម្បីឱ្យអ្នករាល់គ្នាបានសំដែងចេញឱ្យឃើញ អស់ទាំងលក្ខណៈរបស់ព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាចេញពីសេចក្តីងងឹត មកក្នុងពន្លឺអស្ចារ្យរបស់ទ្រង់"។ ពេត្រុស ទី១ ២:៩

# បុព្វកថា

ពេលចាកចេញពីបន្ទប់ងងឹត ហើយឆ្ពោះទៅក្នុងកន្លែងមួយដែលពោរពេញទៅដោយពន្លឺថ្ងៃ ពន្លឺនោះអាចធ្វើឱ្យភ្នែកយើងទៅជាងងឹតបាន ក៏ប៉ុន្តែកាលណាភ្នែករបស់យើងបានផ្លាប់ជាមួយនិងពន្លឺនោះ ពន្លឺនោះអាចធ្វើឱ្យយើងម្នាក់ៗមើលអ្វីៗទាំងអស់បានច្បាស់ និងរីករាយចំពោះទេសភាពទាំងឡាយដែលនៅជុំវិញខ្លួនយើងរាល់គ្នា។

ក្នុងស្ថានភាពដូចគ្នានេះ ពេលដែលយើងសម្លឹងទៅពន្លឺព្រះគម្ពីរ ជួនកាលពន្លឺសច្ចៈធម៌អាចធ្វើឱ្យយើងឈឺចាប់។ ប៉ុន្តែនៅពេលដែលពន្លឺវិញ្ញាណរបស់យើងធ្វើការសម្រុះសម្រួលបាន នោះយើងនឹងមានការសប្បាយរីករាយចំពោះ“ដំណើរក្នុងពន្លឺ”

ការសិក្សាក្នុងព្រះគម្ពីរនេះ គឺជាការរៀបចំមួយដើម្បីអនុញ្ញាតិឱ្យយើង“ដើរ” ឆ្ពោះទៅក្នុងពន្លឺដ៏អស្ចារ្យនៃព្រះបន្ទូល បើយើងឧបមាថា យើងកើតជំនាន់ព្រះយេស៊ូវនិងពួកសាវ័ក ដូចដែលបានចែងពាក្យទុកក្នុងព្រះគម្ពីរ ហើយកំពង់តែអង្គុយស្តាប់នូវការបង្រៀន និងការទេសនាអំពីការសង្គ្រោះ។ ដើម្បីធ្វើនូវកិច្ចការទាំងនេះ យើងត្រូវមានការប្រុងប្រយ័ត្ន “កាត់ស្រាយព្រះបន្ទូលនៃសេចក្តីពិតដ៏ត្រឹមត្រូវ” (ធីម៉ូថេ ទី២ ២:១៥) ដោយការជញ្ជឹងគិត នៅលើគោលសំខាន់ទាំងបី ដែលមានតាមលំដាប់រៀងនៅក្នុងគម្ពីរសញ្ញាថ្មី ហើយដែលបានភ្ជាប់មកក្នុងសៀវភៅនេះ៖

១. **ការសិក្សាអំពីព្រះយេស៊ូវ**– គឺបកស្រាយព្រះបន្ទូលនិងកិច្ចការរបស់ព្រះយេស៊ូវគ្រិស្ត

២. **សកម្មភាពនៃពួកសាវ័ក** – គឺបកស្រាយអំពីចលនានិងការចែកចាយពាក្យនៃព្រះគម្ពីររបស់ពួកសាវ័ក

៣. **លិខិតនៃសាវ័ក**– គឺបកស្រាយអំពីសំបុត្រដែលបានសរសេរដោយពួកសាវ័ក ទៅព្រះវិហារ ដែលចាប់ផ្តើមនៅក្នុងព្រះគម្ពីរកិច្ចការ

យើងជឿជាក់ថាពាក្យក្នុងព្រះគម្ពីរគឺជាពាក្យរបស់ព្រះពិត “គ្មានពាក្យទំនាយណាក្នុងគម្ពីរ ដែលបកស្រាយបានតាមចិត្តនោះឡើយ” (ពេត្រុស ទី២ ១:២០-២១) ដូច្នេះហើយ អស់គ្រប់យើងរាល់គ្នា ខំប្រឹងប្រែងបង្ហាញនូវពាក្យដ៏ពិតរបស់ព្រះ ដោយគ្មានការបន្ថែមឬបន្ថយនៃការបង្រៀននេះឡើយ (ចោទិយកថា ៤:២ . សុភាសិត ៣០:៥-៦) ហើយនេះក៏មិនមែនជាបំណងរបស់យើងខ្ញុំដែរ ដែលចង់ធ្វើឱ្យអ្នករាល់គ្នា បន្ថយនូវទំនាក់ទំនងផ្ទាល់របស់អ្នកនិងព្រះយើងទេ ឬក៏ចង់ធ្វើឱ្យអ្នករាល់គ្នាបែរមកជឿគំនិតផ្ទាល់របស់យើង ឬមកខាងជំនឿនៃក្រុមណាមួយឡើយ គឺយើងខ្ញុំមានតែបំណងមួយ គឺចង់ចែកចាយការពិតដែលមានសរសេរនៅក្នុងព្រះគម្ពីររួចមកហើយ។ ម្យ៉ាងមួយទៀតគឺចង់ប្រកាសប្រាប់ថា ព្រះគម្ពីរគឺជាអាជ្ញាធរមួយគត់ដែលនាំឱ្យយើងមានការប្រាកដក្នុងខ្លួនយើងម្នាក់ៗ ដើម្បីឱ្យបាននាំឆ្ពោះទៅក្នុងការសង្គ្រោះបាន ព្រោះពាក្យក្នុងព្រះគម្ពីរគឺជាពាក្យរបស់ព្រះ ហើយមិនមែនជាប្រពៃណី ឬទម្លាប់របស់មនុស្សដែលនៅលើលោកីយ៍ទេ ដែលនឹងកាត់ទោសយើងរាល់គ្នាទាំងអស់នៅទីគ្រាបញ្ចប់ ។

សូមឱ្យយើងទាំងអស់គ្នាចាប់ផ្តើមអាន ធីម៉ូថេ ទី២ ៣:១៥-១៦ ដើម្បីចាប់ផ្តើមធ្វើដំណើរឆ្ពោះទៅក្នុងពាក្យរបស់ព្រះ ...........

# ការសិក្សាអំពីព្រះយេស៊ូវ

**យ៉ូហាន ១:១-៥ និង ១៤**

កាលដើមដំបូងមាន__________ហើយព្រះបន្ទូលនោះឯង ជាព្រះហើយក៏បានត្រឡប់ជាសាច់ឈាម ព្រះបន្ទូលរបស់ព្រះយេស៊ូវគង់នៅជាព្រះ

**យ៉ូហាន ១:១១-១៣**

ប៉ុន្តែអស់អ្នកណា ដែលបានជឿទ្រង់ ហើយទទួលទ្រង់ ព្រះនឹងប្រទានអំណាចឱ្យអ្នកទាំងនោះបានត្រឡប់ជា______ គឺកើតមកអំពីព្រះវិញ នៅវេលាយប់មួយព្រះបានពន្យល់ អំពីការកើតជាថ្មីនេះចំពោះមេដឹកនាំរបស់សាសន៍យូដា

**យ៉ូហាន ៣:១៦-២១**

ព្រះយេស៊ូវមានបន្ទូលទៅនីកូដេម៉ាសថា បើអ្នកណាចង់ឃើញឬចូលក្នុងនគររបស់ព្រះនោះ អ្នកនោះត្រូវតែកើតអំពី___ ហើយនិងអំពី__________

**យ៉ូហាន ៣:១៦-២១**

ព្រះយេស៊ូវបានប្រាប់នីកូដេម៉ាសថា អ្នកណា________ដល់ព្រះនោះនិងឱ្យមានជីវិតអស់កល្បជានិច្ចវិញ ព្រះយេស៊ូវក៏បានមានបន្ទូលទៀតថា មានការពីរយ៉ាងដែលខុសពីគ្នានៅក្នុងសេចក្ដីសង្គ្រោះ ទី១គឺកើតម្ដងទៀត មួយទៀតគឺមានជំនឿដល់ព្រះ ម្យ៉ាងវិញទៀតនេះក៏ជាមិនមែនជាកាផ្ទុយឡើយ វគ្គនៅក្នុងព្រះគម្ពីរបន្ទាប់នេះនិងបកស្រាយ អំពីទំនាក់ទំនង នៃការជំនឿ ទៅនឹងការពិសោធន៍ នៃកំណើតរបស់ព្រះវិញ្ញាណ។

**យ៉ូហាន ៧:៣៨-៣៩**

នេះគឺបានឱ្យឃើញថា បើយើងជឿដល់ព្រះ (ដោយយោលទៅតាមព្រះបន្ទូល) យើងនិងបានទទួល___________ យើងឃើញថា ជំនឿតាមព្រះគម្ពីរ គឺមានការប្ដូរច្រើនជាជាងការដែលយើងរាល់គ្នាគិត ម្យ៉ាងទៀតគឺអាចផ្ដល់នូវការពិសោធន៍នៃពាក្យក្នុងព្រះគម្ពីរ ។

**យ៉ូហាន ១២:៣៥-៣៦ និង ៤២-៤៣**

ថ្ងៃនេះគឺដូចជាកាលពីជំនាន់ព្រះយេស៊ូវដែរ មានមនុស្សភាគច្រើនជឿដល់ព្រះអង្គ ក៏ប៉ុន្តែពួកអ្នកទាំងនោះមិនហ៊ាន______ ចំពោះព្រះដោយសារខ្លាចចំពោះពួកអ្នកដទៃឯទៀតនិយាយ ឬមានបំណងអ្វីមួយទៅលើពួកគេ ។

**យ៉ូហាន ១២:៤៤-៤៨**

ក្នុងការឆ្លើយតបចំពោះសេចក្ដីខ្លាចរបស់ពួកគេនោះ ព្រះយេស៊ូវបានព្រមានថា______របស់ព្រះនិងកាត់ទោសដល់អ្នករាល់គ្នា ហេតុដូច្នេះហើយយើងត្រូវតែមានការប្រុងប្រយ័ត្ន ដោយកុំឱ្យបដិសេធពាក្យរបស់ព្រះឡើយ គឺត្រូវជឿហើយនិងគោរពពាក្យទាំងនោះ ទោះបីជាអ្នកណានិយាយ ឬក៏ធ្វើអ្វីក៏ដោយ ។

ឈ្មោះមាន ១៧:១៧-២០(២)

នៅក្នុងការអធិស្ឋានរបស់ព្រះយេស៊ូវឱ្យចំពោះពួកសាវ័ក គឺនៅមុនពេលព្រះអង្គបានត្រូវយកទៅឆ្កាង ព្រះបានមានបន្ទូលថា ពាក្យរបស់ព្រះគឺជាពាក្យ------។ គ្រាជាមួយគ្នានោះព្រះក៏បានអធិស្ឋានឱ្យយើងព្រមទាំងអ្នកដែលបានជឿព្រះនៅតាមពាក្យរបស់ពួកសាវ័ក។

ដើម្បីបញ្ជាក់ឱ្យឃើញថា តើពាក្យរបស់ពួកសាវ័កមានន័យដូចម្ដេចនោះ សូមឱ្យយើងអានអ្វីៗដែលព្រះយេស៊ូវបានប្រាប់ទៅពួកសាវ័កឱ្យប្រកាសឡើង។ ព្រះបណ្ដាំយ៉ាងសំខាន់ ក្នុងព្រះគម្ពីរ លូកា ២៤:៤៥-៤៩ (៣) ដែលនឹងផ្ដល់ឱ្យបន្ទាប់ទៅនេះគឺបានធ្វើឡើង ក្រោយដែលព្រះអង្គចូលទីវង្គត់ ហើយព្រះសពបានយកទៅបញ្ចុះ រួចបានមានព្រះជន្មឡើងវិញ ........ នៅមុនពេលដែលព្រះអង្គ យាងទៅឋានសួគ៌វិញ ។

"នោះទ្រង់ក៏បើកបញ្ញាស្មារតីគេ ឲ្យបានយល់ពាក្យនៃគម្ពីរ ទ្រង់មានបន្ទូលទៅគេថា គឺសេចក្ដីនេះហើយដែលបានចែងទុកមក គឺថា ព្រះគ្រីស្ទត្រូវរងទុក្ខលំបាក ហើយនៅថ្ងៃទី៣ ទ្រង់នឹងរស់ពីស្លាប់ឡើងវិញ ហើយត្រូវឲ្យមានការប្រែចិត្តនិងសេចក្ដីប្រោសឲ្យរួច បានប្រកាសប្រាប់ដល់អស់ទាំងសាសន៍ដោយនូវព្រះនាមទ្រង់ចាប់តាំងពីក្រុងយេរូសាឡិមទៅ អ្នករាល់គ្នាជាស្មរបន្ទាល់ពីការទាំងនេះ ហើយមើលខ្ញុំនឹងឲ្យសេចក្ដីសន្យារបស់ព្រះវរបិតា មកសណ្ឋិតលើអ្នករាល់គ្នា ចូរអ្នករាល់គ្នានៅតែក្នុងក្រុងយេរូសាឡិម ដរាបដល់ព្រះចេស្ដាពីស្ថានលើ បានមកគ្របសង្កត់លើអ្នករាល់គ្នា"

តើពួកសាវ័កទាំងនោះ បានបង្រៀននៅពាក្យដែលព្រះយេស៊ូវ បានបញ្ជាឲ្យអ្នកទាំងនោះប្រកាសឡើងដែរឬទេ?
តើសេចក្ដីសន្យារបស់ព្រះវរបិតា បានបំពេញដូចម្ដេចដែរ?

សូមយើងចាប់ផ្ដើមបន្តដំណើរ ទៅក្នុងបន្ទូលរបស់ព្រះ ហើយនឹងអាចឃើញ ថាអ្វីទៅដែលបានបង្រៀន នឹងបានកើតឡើងនៅយេរូសាឡិម.............

# សកម្មភាពរបស់ពួកសាវ័ក

**កិច្ចការ ១:៣-៥**

នៅពេលយើងចាប់ផ្តើមក្នុងព្រះគម្ពីរកិច្ចការ យើងអាចឃើញភ្លាមថា ការសន្យារបស់ព្រះវរបិតា គឺបុណ្យជ្រមុជទឹក ដោយ------- -------------។

**កិច្ចការ ២:១-១៧**

នៅទីក្រុងយេរូសាឡិម ពួកសាវ័កជាមួយនិងពួកមនុស្សជាច្រើនទៀត មានការរីករាយ រួចគេបានពេញជាព្រះវិញ្ញាណបរិសុទ្ធទាំងអស់គ្នា ហើយតាំងបាននិយាយ-----------តាមដែលព្រះវិញ្ញាណប្រទានឱ្យ។ មានមនុស្សជាច្រើនសាសន៍ដែលឈរមើលនោះ មានសេចក្តីអស្ចារ្យ ដែលគេបានឮពួកក្នុងជុំនុំនោះនិយាយជាភាសាជាតិរបស់ខ្លួន ហើយគេក៏សួរថា "តើការនេះមានន័យដូចម្តេច?" ពេលនោះពេត្រុសបានពន្យល់ពីការសន្យានៃការបញ្ជូនមកនូវព្រះវិញ្ញាណ ហើយក៏បន្តការបង្រៀនអំពីព្រះគ្រិស្ទ និងផែនការនៃការសង្គ្រោះ តាមរបៀបពួកសាវ័កជំនាន់ដើម ។

**កិច្ចការ ២:៣៦-៣៩ (៤)**

កាលពួកមនុស្សដែល បានឮពាក្យរបស់ពេត្រុស ហើយជឿថា ព្រះយេស៊ូវ គឺជាព្រះរបស់គេនិងក៏ជាព្រះដែលបានជួយរំដោះបាបផងនោះ ពួកគេក៏មានការសោកស្តាយចំពោះអំពើបាបដែលគេបានធ្វើ ហើយគេក៏សួរទៅពេត្រុសនឹងពួកសាវ័កថា តើគេត្រូវធ្វើដូចម្តេច។ ពេត្រុសបានតបដោយបង្រៀននូវពាក្យរបស់ព្រះយេស៊ូវ ដែលបានបញ្ជារ ឱ្យបង្រៀនទៅតាមព្រះគម្ពីរ លូកា ២៤:៤៥-៤៩ ដើម្បីនឹងបំភ្លឺសេចក្តីនេះ។ សូមពិចារណានៅលើគោលការណ៍សំខាន់ ៣ អំពីផែនការសំរាប់ការសង្គ្រោះ ដែលពេត្រុសបានបង្រៀនក្នុងវគ្គទី ៣៨:

**១. ការប្រែចិត្ត**

**២. ការទទួលបុណ្យជ្រមុជទឹក ក្នុងព្រះនាមព្រះយេស៊ូវគ្រិស្ទ ប្រយោជន៍ឱ្យរួចពីបាប**

**៣. ការទទួលអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ**

**ការសំគាល់ ៖** គម្ពីរកិច្ចការ ២:៣៨ ជាការបំពេញនៃការចាំបាច់ទាំងពីរ "ការកើតជាថ្មី" ដែលព្រះយេស៊ូវមានបន្ទូល នៅក្នុងយ៉ូហាន ៣:៥ ដែលជាការចាំបាច់ដើម្បីឱ្យបានចូលទៅក្នុងនគររបស់ព្រះបាន!

ការកើតអំពីទឹក - ធ្វើបុណ្យជ្រមុជទឹក នៅក្នុងព្រះនាមព្រះយេស៊ូវគ្រិស្ទ!

ការកើតដោយព្រះវិញ្ញាណ - ដែលបានបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ!

ឥឡូវនេះ យើងនឹងចាប់ផ្តើមមើល នៅឧទាហរណ៍ចំពោះមនុស្សខ្លះ ដែលបានកើតម្តងទៀតដោយសាការបុណ្យជ្រមុជទឹក និងព្រះវិញ្ញាណបរិសុទ្ធ ដូចដែលពាក្យព្រះយេស៊ូវ បានផ្តល់ឱ្យចំពោះពួកសាវ័ករបស់ព្រះអង្គ បន្តការបង្រៀនក្នុងព្រះគម្ពីរកិច្ចការទាំងអស់........

## ភីលីពបានផ្សាយដំណឹងល្អទៅចំពោះជនជាតិសាម៉ារី ក្នុងព្រះគម្ពីរកិច្ចការ ជំពូកទី ៨.....

**ការសំគាល់** ៖ មានមនុស្សខ្លះនិយាយថា គេធ្លាប់មានការីករាយសប្បាយ គឺនៅពេលដែលគេបានជឿក្នុងព្រះយេស៊ូវ ឬនៅពេលដែលគេបានធ្វើបុណ្យជ្រមុជទឹក ហើយបន្ទាប់មកគេក៏បានទទួលព្រះវិញ្ញាណបរិសុទ្ធតែម្តង តើពាក្យនៅក្នុងព្រះគម្ពីរបាននិយាយថាដូចម្តេចវិញ?

កិច្ចការ ៨:៥-៨ តើពួកគេបានទទួលការសប្បាយរីករាយមែនឬទេ? បានមែន---- មិនបាន----

វគ្គ ១២ តើគេបានជឿដល់ព្រះយេស៊ូវមែនឬទេ? បានជឿ---- មិនជឿ----

វគ្គ ១៤-១៧ តើគេបានធ្វើបុណ្យជ្រមុជទឹកក្នុងនាមព្រះអង្គទេ? បានធ្វើ---- មិនបាន----

តើគេបានទទួលព្រះវិញ្ញាណបរិសុទ្ធដោយឡែក បានមែន---- មិនបាន----
ពីគ្នាហើយនិងដោយការពិសោធន៏ច្បាស់ឬទេ?

## ពេត្រុសបានផ្សាយដំណឹងល្អដល់សាសន៍ដទៃ ក្នុងព្រះគម្ពីរកិច្ចការ ជំពូកទី ១០

**ការសំគាល់** ៖ មានមនុស្សខ្លះនិយាយថា មានតែជំនឿនោះជាការគ្រប់គ្រាន់ហើយ ឬថាការធ្វើបុណ្យជ្រមុជទឹកដោយព្រះវិញ្ញាណ និងបាននិយាយភាសាផ្សេងនោះ គឺជាភស្តុតាងសំរាប់តែនៅបុណ្យថ្ងៃទី៥០ប៉ុណោះ បើព្រះគម្ពីរថែងថា នេះជាការពិត ការទាំងនោះគឺពិតមែន ក៏ប៉ុន្តែបើពាក្យក្នុងគម្ពីរ ដែលបង្ហាញតាមរយៈការពិសោធន៍ របស់កូនេលាសថា មិនពិតនោះ...ការនោះគឺមិនពិតដែរ ។

កិច្ចការ ១០:១-២ តើកូនេលាសជាអ្នកមានជំនឿមែនឬទេ? មែន---- មិនមែន----

វគ្គ ៥-៦ (៦) តើព្រះបានឱ្យអ្វីទៀតចំពោះគាត់ឬទេ? បានឱ្យ--- មិនបានឱ្យ---

វគ្គ ៤៤-៤៦ តើគេបានទទួលព្រះវិញ្ញាណ ហើយបាននិយាយ
ភាសាផ្សេងទៀត បន្ទាប់អំពីថ្ងៃបុណ្យទី ៥០ ? បានទទួល--- មិនបាន---

វគ្គ ៤៧-៤៨ តើគេត្រូវតែទទួលបុណ្យជ្រមុជទឹក នៅក្នុងព្រះ
នាមព្រះយេស៊ូវដែរឬទេ? មែន---- មិនមែន----

## ប៉ុលផ្សាយដំណឹងល្អចំពោះទៅសាវ័ករបស់យ៉ូហាន គឺមាននៅក្នុងគម្ពីរកិច្ចការទី១៩

**ការសំគាល់** ៖ មានមនុស្សជាច្រើនដែលជាអ្នកមានជំនឿ ក៏ប៉ុន្តែមិនដែលឮអ្វីអំពីព្រះវិញ្ញាណបរិសុទ្ធ ថានេះគឺជាសេចក្តីសន្យាសំរាប់ពួកគេទាំងនោះឡើយ ម្យ៉ាងវិញទៀត អ្នកខ្លះនិយាយថា ការធ្វើបុណ្យជ្រមុជទឹកឬការធ្វើបុណ្យជ្រមុជទឹកជាថ្មីនោះ មិនជាការចាំបាច់ទេ (តែបើអ្នកបានធ្វើបុណ្យជ្រមុជទឹកដោយរបៀបលោកយ៉ូហាននោះ តើអ្នកមានគិតថា វាជាការចាំបាច់ក្នុងការធ្វើបុណ្យជ្រមុជទឹកជាថ្មីម្តងទៀត ដោយប្រកាន់យកនូវការជ្រមុជទឹករបៀបផ្សេងឬទេ?)មានអ្នកខ្លះទៀតនិយាយថា វាមិនសំខាន់ទេ ចំពោះពាក្យដែលនិយាយ នៅក្នុងពេលដែលបានជ្រមុជទឹក។ តែបើព្រះគម្ពីរថែងថា វាមិនជាការសំខាន់ នោះជាការមិនសំខាន់មែន ក៏ប៉ុន្តែ... បើព្រះគម្ពីរបង្ហាញយើងថាអ្វីៗនោះជាការសំខាន់ទៅវិញ?

កិច្ចការ ១៩:១-២ តើអ្នកដែលជឿទាំងនោះ បានឮហើយមានបាន
ទទួលព្រះវិញ្ញាណបរិសុទ្ធឬទេ? បាន____ មិនបាន___

វគ្គ៣-៥ (៧) តើអ្នកទាំងនោះដែលបានធ្វើបុណ្យជ្រមុជទឹករបស់
លោកយ៉ូហាន បានធ្វើបុណ្យជ្រមុជទឹកជាថ្មី
ដែលនៅក្នុងព្រះនាមព្រះយេស៊ូវដែរឬទេ? បាន___ មិនបាន___

វគ្គ៦ ការទទួលព្រះវិញ្ញាណបរិសុទ្ធ ឱ្យមកសណ្ឋិត
លើគេនោះ តើអ្នកទាំងនោះបានមាននិយាយភាសា
ដទៃ ដែលជាភស្តុតាងឬទេ? បាន___ មិនបាន___

**យើងបានឃើញថា ពួកសាវ័កបានផ្សាយដំណឹងល្អ អំពីផែនការនៃការសង្គ្រោះដូចមានចែងខាងក្រោមនេះ:**

...ជីវិតនិងការសុគតរបស់ព្រះគ្រិស្ទ ការកប់ និងការមានជីវិតរស់ឡើងវិញ

...ការប្រែចិត្តចំពោះព្រះ និងជឿក្នុងព្រះយេស៊ូវគ្រិស្ទ

...ការធ្វើបុណ្យជ្រមុជទឹក ដោយជ្រមុជក្នុងទឹក នៅក្នុងនាមព្រះយេស៊ូវគ្រិស្ទ

...ដោយបានទទួលអំណោយទាន នៃព្រះវិញ្ញាណបរិសុទ្ធ (ដែលបានមកសណ្ឋិត និងបាននិយាយនៃភាសាដទៃទៀត ដែលជាភស្តុតាងផង)

ឥឡូវនេះ សូមយើងអាន អំពីដំណឹងល្អនៃសេចក្តីសង្គ្រោះ ដែលពួកសាវ័កបានប្រកាសនៅក្នុងព្រះគម្ពីរកិច្ចការ យើងអាចធ្វើកិច្ចការនេះ ដោយអានសំបុត្ររបស់ពួកសាវ័ក ដែលគេបានសសេរទៅកាន់ពួកជំនុំសាសនាដោយស្នាដៃគេ។

# ឆ្ពោះទៅកាន់ លិខិតនៃសាវ័ករបស់ព្រះ

ដូចយើងបានអានទូវលិខិតនៃសាវ័ករបស់ព្រះ យើងនឹងកត់សំគាល់ឃើញថា តើសាវ័កទាំងនោះមានអារម្មណ៍រឹងមាំយ៉ាងណា ចំពោះ"ដំណឹងល្អ"នៃពិធីសង្គ្រោះ។ នេះពុំមែនដោយសារ អ្នកទាំងនោះជាអ្នកកាត់ទោស (វិនិច្ឆ័យ)ទោសនោះឡើយ គឺដោយសារ គេបានដឹងថាព្រះបន្ទូលរបស់ព្រះយេស៊ូវ ដែលបានប្រគល់ដល់គេឱ្យប្រកាសនេះ នឹងវិនិច្ឆ័យមនុស្សគ្រប់រូបទាំងអស់ ។

**តើពេត្រុសបាននិយាយថាដូចម្តេច?**

"អ្នករាល់គ្នាបានជំរះសំអាតចិត្ត ដោយស្តាប់តាមសេចក្តីពិត... ដោយសារព្រះបន្ទូល... គឺជាព្រះបន្ទូលដែលបានផ្សាយមកអ្នករាល់គ្នាហើយ" (ពេត្រុស ទី១ ១:២២-២៥)

ការគោរពព្រះបន្ទូល ដើម្បីជំរះសំអាតចិត្តរបស់យើង

**ពេត្រុសសួរសំនួរមួយ ៖**

"តើចុងបំផុត របស់ពួកអ្នកដែលមិនគោរពតាមដំណឹងល្អនៃព្រះ នឹងបានជាយ៉ាងដូចម្តេច?"

(ពេត្រុសទី១ ៤:១៧-១៨)

**ប៉ុលបានឱ្យនូវចំឡើយ ៖**

"ព្រះអម្ចាស់យេស៊ូវ ទ្រង់លេចមកពីស្ថានសួគ៌ ជាមួយនឹងពួកទេវតានៃព្រះចេស្តាទ្រង់ នៅក្នុងអណ្តាតភ្លើង ទាំងសងសឹកនឹងពួកអ្នកដែលមិនស្គាល់ព្រះ ហើយនឹងពួកអ្នកមិនស្តាប់តាមដំណឹងល្អពីព្រះយេស៊ូវគ្រិស្ទ ជាព្រះអម្ចាស់នៃយើង គេនឹងរងទុក្ខទោស ជាសេចក្តីហិនវិនាសអស់កល្បជានិច្ច ឃ្លាតពីព្រះភក្ត្រនៃព្រះអម្ចាស់ ហើយពីសិរីល្អនៃព្រះចេស្តាទ្រង់"

(ថែស្សាឡូនីច ទី២ ១:៧-៩)

នេះជាសេចក្តីសំខាន់ដែលគ្មានទីបំផុត នូវការគោរពព្រះបន្ទូល!

**តើប៉ុលបាននិយាយថាដូចម្តេច?**

"ខ្ញុំឆ្ងល់ណាស់ពី ដំណើរដែលអ្នករាល់គ្នាបានផ្លាស់ប្រែចេញពីព្រះ ដែលទ្រង់ហៅអ្នករាល់គ្នាមក ក្នុងព្រះគុណនៃព្រះគ្រិស្ទ ជាឆាប់ម្ល៉េះ នឹងទៅតាមដំណឹងល្អផ្សេងទៀតនោះ ដែលមិនមែនជាដំណឹងល្អ១ទៀតទេ គឺមានមនុស្សខ្លះបំភាន់អ្នករាល់គ្នាវិញ ហើយចង់បង្ខូចដំណឹងល្អព្រះគ្រិស្ទផង ប៉ុន្តែ បើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌ នឹង ប្រាប់ដំណឹងណាមកអ្នករាល់គ្នាខុសពីដំណឹងល្អ ដែលយើងខ្ញុំបានប្រាប់ហើយ នោះឱ្យគេត្រូវបណ្តាសាចុះ ឯសេចក្តីដែលខ្ញុំទើបនឹងនិយាយអម្បាញ់មិញនេះ នោះខ្ញុំនិយាយម្តងទៀតថា បើអ្នកណាប្រាប់ដំណឹងណា ខុសពីដំណឹងល្អ ដែលអ្នករាល់គ្នាបានទទួលហើយ នោះឱ្យគេត្រូវបណ្តាសាចុះ" (កាឡាទី ១:៦-៩)

គឺមានព្រះបន្ទូលតែព្រះមួយគត់ !

**តើយ៉ាកុបបាននិយាយដូចម្ដេច?**

"ចូរទទួលព្រះបន្ទូលដែលបានដាំក្នុងចិត្តអ្នករាល់គ្នា ដោយចិត្តសុភាពចុះ ដ្បិតព្រះបន្ទូលនោះអាចនឹងជួយសង្គ្រោះព្រលឹងអ្នករាល់គ្នាបាន ចូរឲ្យអ្នករាល់គ្នាប្រព្រឹត្តតាមព្រះបន្ទូលទៅ កុំឲ្យគ្រាន់តែស្ដាប់ប៉ុណ្ណោះ ហើយបញ្ឆោតខ្លួនវិញនោះឡើយ ដ្បិតបើអ្នកណាស្ដាប់ព្រះបន្ទូលហើយ តែមិនប្រព្រឹត្តតាម អ្នកនោះធៀបដូចជាមនុស្សដែលឆ្លុះមុខក្នុងកញ្ចក់ អ្នកនោះគ្រាន់តែមើលខ្លួន រួចចេញបាត់ទៅ ហើយក៏ភ្លេចពីបែបភាពខ្លួនជាយ៉ាងណាភ្លាម" (យ៉ាកុប ១:២១-២៥)

ព្រះបន្ទូលគឺអាចជួយសង្គ្រោះព្រលឹងយើងរាល់គ្នាបាន

យ៉ាកុបប្រាប់យើងរាល់គ្នាថា បើយើងឃើញអ្វីដែលយើងត្រូវការធ្វើ ត្រូវយើងក្រឡេកមើលទៅក្នុង "កញ្ចក់នៃព្រះបន្ទូល" យើងអាចប្រព្រឹត្តបាន។ ឥឡូវសូមយើងពិចារណា ថាអ្វីដែលនឹងប្រព្រឹត្ត ជាមួយអ្វីដែលយើងបានឮ...

## សេចក្ដីបញ្ចប់

តើអ្នកជឿថាព្រះបន្ទូលគឺជាពាក្យពិត ហើយនឹងវិនិច្ឆ័យដល់យើងរាល់គ្នាដែរឬទេ?

តើអ្នកជឿថាយេស៊ូវគ្រិស្ដជា ព្រះនឹងជាព្រះសង្គ្រោះឬទេ?

តើអ្នកជឿថា ការប្រែចិត្តវាជាការសំខាន់ ដើម្បីឲ្យអ្នកលះបង់នៅអំពើបាបចេញ ហើយនឹងប្រគល់ជីវិតរបស់យើងដល់ព្រះឬទេ?

តើអ្នកជឿថា ពិធីជ្រមុជទឹកនៅក្នុងព្រះនាមយេស៊ូវគ្រិស្ទ គឺជារបៀបដែលព្រះគម្ពីរបានចែងមកដែរឬទេ?

តើអ្នកជឿថា ការជ្រមុជទឹក ដោយនៅព្រះវិញ្ញាណបរិសុទ្ធនៅវេលាសព្វថ្ងៃនេះ នឹងនៅពេលដែលនិយាយភាសារមួយទៀតនោះ តើដូចនៅពេលដែលបានកើតឡើងនៅក្នុងព្រះគម្ពីរដែរឬទេ?

**បើអ្នកជឿអ្វីៗនៅខាងលើនេះ សូមអធិស្ឋានក្នុងពេលនេះ ដើម្បីសុំព្រះអនុញ្ញាតិឲ្យអ្នកបានទទួលការពិសោធន៍ទាំងអស់ដែលព្រះមាន មកដល់អ្នក !**

## ការសិក្សាបន្ថែម អំពីព្រះគម្ពីរ

(១)ម៉ាថាយ ៧:១៣-២៤

ការសំគាល់ ៖ សេចក្តីព្រមានរបស់ព្រះ ចំពោះហោរាក្លែងក្លាយ និងសេចក្តីសំខាន់ នៃការអនុវត្តនូវព្រះបន្ទូល និងការដែលគ្រាន់តែឮព្រះបន្ទូល

(២)ម៉ាថាយ ៦:១៥-១៩

ការសំគាល់ ៖ ពេត្រុសបានទទួល"សោរនៃព្រះរាជាណាចក្រ" ពីព្រោះពេត្រុសបានស្គាល់ថាព្រះយេស៊ូវជាអ្នកណា

(៣)"គណៈកម្មការដ៏ធំ" មួយទៀតនៃព្រះគម្ពីរ

ការសំគាល់ ៖ ក្នុងម៉ាថាយ ២៨:១៨-២០ ពាក្យថា"ឈ្មោះ" គឺជាឯកវចនៈ (គឺមានតែមួយ) ក្នុងសេចក្តីបញ្ជារ ក្នុងការធ្វើបុណ្យជ្រមុជទឹក។ សាវ័កទាំងអស់ គោរពបញ្ជារនេះ ដោយធ្វើបុណ្យជ្រមុជទឹកតែនៅក្នុងព្រះនាម ព្រះយេស៊ូវ ហើយគេពុំបានប្រើនូវ មុខងារទាំងអស់នោះឡើយ (សូមអាន កិច្ចការ ៤:១២)

ម៉ាកុស ១៦:១៥-១៨ សារៈសំខាន់នៃការធ្វើបុណ្យជ្រមុជទឹក និងសញ្ញាដែលបញ្ជាញដល់អ្នកមានជំនឿ

(៤)ម៉ាថាយ ១៦:១៥-១៩

ការសំគាល់ ៖ ពេត្រុស ដែលបានទទួល"សោរនៃព្រះអាណាចក្រ" បានយកសោរនោះទៅបើក "ទ្វារនៃព្រះរាជាណាចក្រ" ដោយធ្វើការសំដែងពន្យល់ តាមលំនាំជំនាន់ដើម នៃពិធីទទួលការសង្គ្រោះ នៅលើកទីមួយ

(៥)កិច្ចការ ៨:៣៥-៣៩

ការសំគាល់ ៖ ភីលីព ពិតជាបានលើកអំពីពិធីធ្វើបុណ្យជ្រមុជទឹក និងអំពីដំណឹងល្អរបស់ព្រះយេស៊ូវប្រាប់ដល់អឺណោច ហេតុដូច្នោះហើយបានជាអឺណោច សុំទទួលធ្វើបុណ្យជ្រមុជទឹក។ ដើមកំណើតពាក្យថា ការធ្វើបុណ្យជ្រមុជទឹក ជាភាសាក្រិច មានន័យថា"ជ្រមុជឱ្យលិចចូលទៅក្នុងទឹក" (អាន រ៉ូម ៦:៣-៤)

(៦)កិច្ចការ ១០:៣៤-៤៣

ការសំគាល់ ៖ ពេត្រុសសំដែងអំពីដំណើរជីវិត និងលក្ខណជាព្រះអម្ចាស់នៃព្រះយេស៊ូវគ្រិស្ត ព្រមជាមួយនិង ការចូលទីវង្គត់ ការបញ្ចុះព្រះសព ហើយនិងការរស់ឡើងវិញ របស់ព្រះអង្គ។

(៧)ពេត្រុស ទី១ ៣:២០-២១

ការសំគាល់ ៖ យោលទៅតាមលោកពេត្រុស ពិធីបុណ្យជ្រមុជទឹក ជាផ្នែកមួយសំខាន់នៃគំរោងការនៃការសង្គ្រោះ។

យើងសូមឱ្យអ្នករៀននូវ សកម្មភាពព្រះយេស៊ូវ សកម្មភាពនៃពួកសាវ័ក និងលិខិតនៃពួកសាវ័ក ហើយបន្តរដំណើររបស់អ្នក"ឆ្ពោះទៅកាន់ព្រះពន្លឺដ៏អស្ចារ្យរបស់ព្រះ"



http://www.sayadi-al-nas.com